**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥១ និងកិច្ចប្រជុំពាក់ព័ន្ធ
## ថ្ងៃទី១-៤ ខែសីហា ឆ្នាំ២០១៨ ប្រទេសសឹង្ហបុរី

*****

ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំគណៈ ប្រតិភូចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥១ និងកិច្ចប្រជុំពាក់ព័ន្ធ ពីថ្ងៃទី ០១ ដល់០៤ ខែសីហា ឆ្នាំ២០១៨ នៅប្រទេសសឹង្ហបុរី។ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៅឆ្នាំនេះ ដែលប្រព្រឹត្តទៅក្រោមមូលបទ "**ភាពរឹងមាំ និងនវានុវត្ត**" គឺជាជំនួបដ៏សំខាន់របស់រដ្ឋមន្ត្រីការបរទេសអាស៊ាន ដើម្បីពិភាក្សា និងតាមដានកិច្ចប្រឹងប្រែងរបស់អាស៊ានក្នុងការកសាងសហគមន៍ និងសមាហរណកម្មសេដ្ឋកិច្ច។ កិច្ចប្រជុំនេះក៏ផ្តល់ឱកាសដល់រដ្ឋមន្ត្រីការបរទេសអាស៊ាន ក្នុងទំនាក់ទំនងប្រកបដោយន័យស្ថាបនា ជាមួយសមភាគីក្នុងយន្តការដែលដឹកនាំដោយអាស៊ានផ្សេងទៀត ដើម្បីធ្វើឲ្យស៊ីជម្រៅ និងពង្រឹងទំនាក់ទំនងខាងក្រៅរបស់អាស៊ាន។

ឯកឧត្តមទេសរដ្ឋមន្ត្រី រួមជាមួយរដ្ឋមន្ត្រីការបរទេសពីប្រទេសសមាជិកអាស៊ាន បានចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម លី សៀន ឡុង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសឹង្ហបុរី។

រដ្ឋមន្ត្រីបានពិភាក្សាប្រកបដោយអត្ថន័យ និងផ្លាស់ប្តូរទស្សនៈទាក់ទងនឹងបញ្ហាតំបន់ និងអន្តរជាតិ ដែលមានផលប្រយោជន៍រួម ដូចជា ការវិវត្តនៅសមុទ្រចិនខាងត្បូង ស្ថានការណ៍នៅឧបទ្វីបកូរ៉េ ការប្រយុទ្ធប្រឆាំងភេរវកម្ម និងហឹង្សាជ្រុលនិយម សន្តិសុខលំហសមុទ្រ ក៏ដូចជាសន្តិសុខប្រពៃណី និងមិនប្រពៃណីផ្សេងទៀត។ ក្នុងរយៈពេលកិច្ចប្រជុំ៤ថ្ងៃនេះ ឯកឧត្តមទេសរដ្ឋមន្ត្រីបានធ្វើបទអន្តរាគមន៍ លើបញ្ហាជាច្រើន ដែលចំណុចសំខាន់ៗ មានដូចខាងក្រោមៈ

- អំពីស្ថានភាពនៅឧបទ្វីបកូរ៉េ ឯកឧត្តមទេសរដ្ឋមន្ត្រីបានស្វាគមន៍លទ្ធផលកិច្ចប្រជុំកំពូលអន្តរកូរ៉េ នៅក្នុងខែមេសា និងឧសភា ឆ្នាំ២០១៨ កិច្ចប្រជុំកំពូលបីលើករវាងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងចិន និងកិច្ចប្រជុំកំពូលជាប្រវត្តិសាស្ត្ររវាងសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ នៅខែមិថុនា ឆ្នាំ២០១៨។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានស្វាគមន៍ "សេចក្តីប្រកាស បានមុនចម (Panmunjeom) ដើម្បីសន្តិភាព វិបុលភាព



អាសយដ្ឋានៈ លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

និងឯកភាពឧបទ្វីបកូរ៉េ" និង " សេចក្តីថ្លែងការណ៍រួមរវាងសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ" ដែលជាជំហានដ៏សំខាន់ឆ្ពោះទៅការរំសាយអាវុធនុយក្លេអ៊ែរទាំងស្រុងនៅឧបទ្វីបកូរ៉េ។ ស្របជាមួយនឹងទស្សនៈរបស់រដ្ឋមន្ត្រីផ្សេងទៀតដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្តភាគីពាក់ព័ន្ធទាំងអស់ អនុវត្តឲ្យបានពេញលេញនូវការប្តេជ្ញាចិត្តនានា ដើម្បីធ្វើជាមូលដ្ឋានសម្រេចឲ្យបានសន្តិភាព និងការរំសាយអាវុធនុយក្លេអ៊ែរទាំងស្រុងនៅឧបទ្វីបកូរ៉េ។

- ចំពោះបញ្ហាសមុទ្រចិនខាងត្បូង ឯកឧត្តមទេសរដ្ឋមន្ត្រីបានទទួលស្គាល់ថា ការវិវឌ្ឍជាវិជ្ជមានដោយបានឯកភាពនូវ "សេចក្តីព្រាងអត្ថបទចរចារួមមួយស្តីពីក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង"។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ឡើងវិញថា អាស៊ាន និងចិន បានបង្ហាញថា ទំនុកចិត្តរួមជាមួយកិច្ចសហប្រតិបត្តិការលំហសមុទ្រជាក់ស្តែង វិធានការទទួលផលឆាប់រហ័ស និងការកសាងទំនុកចិត្តអាចនាំមកនូវលទ្ធផលជាវិជ្ជមាន។ ក្នុងដំណើរទៅមុខក្នុងកិច្ចចរចាស្តីពីក្រមប្រតិបត្តិ ឯកឧត្តមទេសរដ្ឋមន្ត្រី បានជំរុញភាគីទាំងអស់បន្តគោរពតាម "ស្មារតីបាលី-សៀមរាប"។
- ក្នុងពេលដែលធ្វើការកត់សំគាល់ពីការព្រួយបារម្ភនានា ជុំវិញភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចសំខាន់ៗ ឯកឧត្តមទេសរដ្ឋមន្ត្រីបានយល់ស្របជាមួយរដ្ឋមន្ត្រីការបរទេសផ្សេងទៀត ពីភាពចាំបាច់ក្នុងការបញ្ចប់ការចរចាស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (Regional Comprehensive Economic Partnership-RCEP) នៅក្នុងដំណាច់ឆ្នាំនេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា RCEP ដែលមានគោលបំណងបង្កើតកិច្ចព្រមព្រៀងទំនើបគ្រប់ជ្រុងជ្រោយ មានគុណភាពខ្ពស់ និងមានផលប្រយោជន៍ទៅវិញទៅមក នឹងជួយទប់ស្កាត់និន្នាការគាំពារនិយមដែលចេះតែកើនឡើង នៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។
- ចំពោះទស្សនៈទានឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលស្នើឡើងជាច្រើន ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់យ៉ាងច្បាស់ ពីភាពចាំបាច់ក្នុងការដម្កល់មជ្ឈភាពអាស៊ាន ជាបេះដូងនៃគំនិតផ្តួចផ្តើមនិម្មាបនកម្មតំបន់។ ដោយទទួលស្គាល់ថាសំណើទស្សនៈទានឥណ្ឌូ-ប៉ាស៊ីហ្វិក នឹងត្រូវយកមកពិភាក្សាថែមទៀតនាពេលអនាគត ឯកឧត្តមទេសរដ្ឋមន្ត្រីបានប្រកាន់ខ្ជាប់នូវជំហរថា គំនិតផ្តួចផ្តើមនេះ ត្រូវមានលក្ខណៈបើកចំហរ បរិយាប័ន្ន និងបំពេញឲ្យគ្នាទៅវិញទៅមកជាមួយនឹងគំនិតផ្តួចផ្តើមផ្សេងៗទៀត និងត្រូវជំរុញការតភ្ជាប់ និងកិច្ចសហប្រតិបត្តិការ ជៀសជាងការបង្កើតការប្រកួតប្រជែង។
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស បានកត់សំគាល់ពីវឌ្ឍនភាពនៃការកសាងសហគមន៍អាស៊ាន ការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន និងផែនការការងារនៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ានដំណាក់កាលទី៣។ រដ្ឋមន្ត្រីបានបញ្ជាក់ពីសារៈសំខាន់ក្នុងការលើកកំពស់ថែមទៀតអំពីទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ជំរុញការតភ្ជាប់ឌីជីថល និងនវានុវត្ត។ ចំពោះទំនាក់ទំនងរវាងប្រជាជន និងប្រជាជន មានការលើកឡើងនូវទស្សនៈជាច្រើនក្នុងការគាំទ្រគំនិតផ្តួចផ្តើមការលើកកម្ពស់អត្តសញ្ញាណអាស៊ានក្នុងចំណោមប្រជាជនអាស៊ាន ទាក់ទង

យុវជនអាស៊ាន ដើម្បីពង្រឹងកិច្ចសន្ទនា និងការយោគយល់គ្នាទៅវិញទៅមករវាងយុវជនដែលមានជំនឿផ្សេងគ្នា។ រដ្ឋមន្ត្រីបានគូសបញ្ជាក់ពីកំណើននៃការប្រើប្រាស់នវានុវត្ត និងបច្ចេកវិទ្យា ដើម្បីកែលំអជីវភាពរបស់ប្រជាជន។ រដ្ឋមន្ត្រីបានកត់សំគាល់ថាបណ្តាញទីក្រុងឆ្លាតរបស់អាស៊ាន គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយ ដែលអាចជាវេទិកាដើម្បីជួយគ្នាទៅវិញទៅមកដល់កិច្ចប្រឹងប្រែងអភិវឌ្ឍ ការចែករំលែកការអនុវត្តល្អៗ និងបង្កើតឱកាសថែមទៀតសម្រាប់កំណើននវានុវត្ត ការកសាងសមត្ថភាព និងការអភិវឌ្ឍប្រកបដោយស្ថិរភាព និងបរិយាប័ន្ន។

ក្រៅពីការចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ក៏មានកិច្ចប្រជុំ៤ដោយឡែកផ្សេងទៀតស្តីពីយន្តការកិច្ចសហប្រតិបត្តិការមេគង្គ រួមមាន កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-គង្គា កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េ លើកទី៨ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសគំនិតផ្តួចផ្តើមមេគង្គក្រោមលើកទី១១ និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១១។

ឯកឧត្តមទេសរដ្ឋមន្ត្រីក៏មានជំនួបទ្វេភាគីជាមួយរដ្ឋមន្ត្រី និងប្រធានគណប្រតិភូពីប្រទេសជាច្រើន រួមមាន រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី រដ្ឋមន្ត្រីការបរទេសចិន រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ អនុរដ្ឋមន្ត្រីការបរទេសឥណ្ឌា រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី រដ្ឋមន្ត្រីការបរទេសជប៉ុន រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី រដ្ឋមន្ត្រីការបរទេសណូវែលហ្សេឡង់ រដ្ឋមន្ត្រីការបរទេសណ័រវែស រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ រដ្ឋមន្ត្រីការបរទេសរុស្ស៊ី រដ្ឋមន្ត្រីការបរទេសស្រីលង្កា រដ្ឋមន្ត្រីការបរទេសទីម័រខាងកើត រដ្ឋមន្ត្រីការបរទេសថៃ និងរដ្ឋមន្ត្រីការបរទេសវៀតណាម ។ កិច្ចប្រជុំទ្វេភាគីទាំងនេះ ផ្តោតសំខាន់លើការពង្រឹងចំណងទ្វេភាគី និងពិភាក្សាពីផលប្រយោជន៍ និងការព្រួយបារម្ភរួម។

ចំពោះព័ត៌មានពិស្តារ សូមអានសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥១ និងសេចក្តីថ្លែងការណ៍របស់ប្រធានកិច្ចប្រជុំនៃកិច្ចប្រជុំពាក់ព័ន្ធ៕

ថ្ងៃអង្គារ ទី១១ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៨